ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

លេខាធិការដ្ឋាន

លេខ: ០៤០.០១៧ /គ.ជ.អ.ប

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៧

នាយកដ្ឋានរដ្ឋបាល & វិនិយោគ
មកដល់: ២១ មេសា ២០១៧
ចុះលេខ: ១៦១/១៧

សាលាខេត្តសៀមរាប
មកដល់ថ្ងៃទី ២០.០៤.១៧
ចុះលេខ ៣៤៩
បញ្ជូនទៅ ទី.ផ្នែកធនធាន

**គោរពជូន**

**ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្ត**

**__កម្មវត្ថុ:__** ស្តីពីការបែងចែកការទទួលខុសត្រូវរបស់ទីប្រឹក្សានិងមន្ត្រីការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ដើម្បីពិនិត្យ និងផ្តល់យោបល់បច្ចេកទេសផ្នែកសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ក្នុងក្របខ័ណ្ឌគម្រោងមូលនិធិឃុំ សង្កាត់ គម្រោងក្រុង ស្រុក និងគម្រោងខេត្ត។

**__យោង:__** ចំណារឯកភាពលើលិខិតសុំលាឈប់ពីការងាររបស់កញ្ញា **ឆាយា សុខ័យ្យា** ជាមន្ត្រីការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ចុះថ្ងៃទី៥ ខែសីហា ឆ្នាំ២០១៦របស់លេខាធិការដ្ឋាន គ.ជ.អ.ប។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមជ្រាបថា កន្លងទៅ លេខាធិការដ្ឋាន គ.ជ.អ.ប បានចាត់លោក **តេ រិទ្ធី** ជាទីប្រឹក្សាការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចឱ្យទទួលបន្ទុកការងារចំនួន១៤ខេត្ត និងកញ្ញា **ឆាយា សុខ័យ្យា** ជាមន្ត្រីការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចឱ្យទទួលបន្ទុកការងារចំនួន១០ខេត្ត ចាប់តាំងពីឆ្នាំ២០១៤មកម្ល៉េះ ក្នុងគោលបំណងដើម្បីពង្រឹងប្រសិទ្ធភាព នៃការគាំទ្រការងារផ្នែកសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចក្នុងក្របខ័ណ្ឌគម្រោងមូលនិធិឃុំ សង្កាត់ គម្រោងក្រុង ស្រុក និងគម្រោងរាជធានីខេត្ត។ ប៉ុន្តែចាប់ពីថ្ងៃទី ៥ ខែសីហា ឆ្នាំ២០១៦ កញ្ញា **ឆាយា សុខ័យ្យា** បានសុំលាឈប់ពីការងារជាមន្ត្រីការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចនៃលេខាធិការដ្ឋាន គ.ជ.អ.ប។ ដើម្បីនិរន្តរភាពនិងប្រសិទ្ធភាពការងារផ្នែកសុវត្ថិភាពទាំងបីនេះ លេខាធិការដ្ឋាន គ.ជ.អ.ប បានជ្រើសរើសមន្ត្រីចំនួនទទួលបន្ទុក០១រូប ជំនួសការងាររបស់មន្ត្រីដែលបានលាឈប់គឺកញ្ញា **ស៊ុន ស៊ីមាត្រ** ដើម្បីជួយពិនិត្យ និងផ្តល់យោបល់បច្ចេកទេសការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន និងជនជាតិដើមភាគតិច និងការចុះត្រួតពិនិត្យឯកសាររបាយការណ៍ដីធ្លីនៅតាមបណ្តាខេត្តនានា។ ដូច្នេះ ដើម្បីដោះស្រាយ និងសម្រួលបន្ទុកការងារ លេខាធិការដ្ឋាន គ.ជ.អ.ប បានសម្រេចធ្វើការបែងចែកការងារឱ្យទីប្រឹក្សា និងមន្ត្រីខាងលើនេះ ដោយបានកំណត់ខេត្តឱ្យទទួលខុសត្រូវ ចាប់ពីថ្ងៃទី ៤ ខែមេសា ឆ្នាំ២០១៧ ដូចខាងក្រោម ៖

១ - លោក **តេ រិទ្ធី** ជាទីប្រឹក្សាការងារកិច្ចការពារសុវត្ថិភាពទទួលខុសត្រូវលើខេត្តចំនួន ១៤ រួមមានខេត្ត៖ កំពង់ឆ្នាំង កំពង់ស្ពឺ មណ្ឌលគិរី ព្រៃវែង ស្វាយរៀង តាកែវ ពោធិ៍សាត់ បាត់ដំបង កំពត កោះកុង ព្រះសីហនុ កែប ព្រះវិហារ និងក្រចេះ។

២ -កញ្ញា **ស៊ុន ស៊ីមាត្រ** ជាមន្ត្រីការងារកិច្ចការពារសុវត្ថិភាពទទួលខុសត្រូវលើខេត្តចំនួន១០ រួមមានខេត្ត៖ កំពង់ចាម កំពង់ធំ កណ្តាល រតនគិរី ស្ទឹងត្រែង សៀមរាប បន្ទាយមានជ័យ ឧត្តរមានជ័យ ប៉ៃលិន និង ត្បូងឃ្មុំ។

ដូច្នេះ សូមលោក លោកស្រីជាមន្ត្រីបង្គោលផ្នែកសុវត្ថិភាពនិងទីប្រឹក្សាពាក់ព័ន្ធថ្នាក់ខេត្តផ្ញើឯកសារគម្រោងដើម្បីពិនិត្យ និងផ្តល់យោបល់បច្ចេកទេសមកលោក **តេ រិទ្ធី** តាមរយៈអ៊ីមែល:<terithy@ncdd.gov.kh>និងកញ្ញា **ស៊ុន ស៊ីមាត្រ** តាមរយៈអ៊ីមែល:<symeat_sun@ncdd.gov.kh >។

អាស្រ័យហេតុនេះ សូមឯកឧត្តម មេត្តាជ្រាប និងចាត់ចែងតាមការគួរ ។

សូមឯកឧត្តម ទទួលនូវការគោរពរាប់អានដ៏ស្មោះអំពីខ្ញុំ។

**ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**

ង៉ាន់ ចំរើន